រដ្ឋ California - ទីភ្នាក់ងារសេវាកម្មមនុស្ស និងសុខភាព

នាយកដ្ឋានសេវាកម្មថែទាំសុខភាព

## អត្ថប្រយោជន៍សុខភាពធ្មេញសម្រាប់មនុស្សពេញវ័យ នៃ Medi-Cal

សមាជិក Medi-Cal ជាទីរាប់អាន៖

នៅពេលមានការយល់ព្រមពីសហព័ន្ធ នោះអត្ថប្រយោជន៍សុខភាពធ្មេញសម្រាប់មនុស្សពេញវ័យនឹងផ្លាស់ប្តូរនៅ**ថ្ងៃទី 1 ខែមករា ឆ្នាំ 2018**។ អត្ថប្រយោជន៍សុខភាពធ្មេញនឹង**មិន**ផ្លាស់ប្តូរសម្រាប់ស្ត្រីមានផ្ទៃពោះ ឬមនុស្សពេញវ័យនៅក្នុងមណ្ឌលថែទាំដោយគិលានុបដ្ឋាកជំនាញ ឬ មធ្យមឡើយ។ អត្ថប្រយោជន៍សុខភាពមាត់ធ្មេញសម្រាប់កុមារ**គ្មាន**ការផ្លាស់ប្តូរទេ។

អ្នកមានសេវាទាំងនេះឥឡូវនេះ៖

- ការពិនិត្យ និងការថតការស្មីអ៊ិច
- ការលាងសម្អាត (ការបង្ការ)
- ការព្យាបាលដោយ Fluoride
- ការប៉ះធ្មេញ
- ការព្យាបាលបណ្តូលធ្មេញខាងមុខ
- ស្រោបធ្មេញដោយអ៊ីណុក
- ធ្មេញពាក់មួយក្រាស់
- សេវាសុខភាពធ្មេញដែលចាំបាច់ផ្សេងទៀត

សេវាកម្មដែលនឹងត្រូវបន្ថែមរួមមាន៖

- ការត្រួតពិនិត្យច្រើនប្រភេទទៀត
- ការសម្អាតយ៉ាងជ្រៅ (សម្អាតកណកកបោរ)
- ស្រោបធ្មេញដោយមន្ទីរពិសោធន៍
- ធ្មេញពាក់ដោយផ្នែក
- ការព្យាបាលបណ្តូលធ្មេញខាងក្រោយ

សេវាផ្នែកធ្មេញអាចផ្តល់ជូនលើសចំនួនកំណត់ $1800 ក្នុងមួយឆ្នាំ ប្រសិនបើគេឃើញថា វាចាំបាច់តាមន័យវេជ្ជសាស្ត្រ។

**សម្រាប់សំណួរ ឬស្វែងរកទន្តពេទ្យ**

- ទូរស័ព្ទទៅ Denti-Cal តាមរយៈ **1-800-322-6384**។ ឬទៅ www.denti-cal.ca.gov។
- ក្នុង Sacramento, ទូរស័ព្ទទៅគម្រោងរបស់អ្នក៖
  - Access Dental៖ 1-877-821-3234
  - Health Net Dental៖ 1-877-550-3868
  - Liberty Dental៖ 1-877-550-3875
- នៅក្នុងខោនធី Los Angeles អ្នកអាចទូរស័ព្ទទៅលេខទាំងនេះ៖
  - Access Dental៖ 1-888-414-4110
  - Health Net Dental៖ 1-800-977-7307

- Liberty Dental៖ 1-888-703-6999

សូមអរគុណ

នាយកដ្ឋានសេវាកម្មថែទាំសុខភាព